# សៀវភៅគតិលោក

## ភាគ ទី៨



សុត្តន្តប្រីជា ឥន្ទ

១៨៥៩ - ១៩២៤

ChanBoKeo.com
កែវ បន្ទុបុរណ

# រឿងតាភោគនឹងក្មេងវត្ត

មានតាចាស់ម្នាក់ឈ្មោះតាភោគ តានោះតាំងលំនៅៗខាងវត្ត លោក គាត់ជាអ្នកឧស្សាហ៍ដាំដំណាំចិញ្ចឹមជីវិត អាស្រ័យដោយផលាផលនៃដំណាំនោះឯង តែគាត់ជាមនុស្សកំណាញ់ពួកកូនក្មេងវត្តនោះវាតែងចូលទៅបេះ បោចដំណាំគាត់តែរឿយៗ ។

ថ្ងៃមួយ តាភោគខឹងនឹងកូនក្មេងវត្តពេកណាស់ទើបទៅពិត ទូលលោកចៅអធិការ ឲ្យលោកជេរវាយហាមកូនសិស្ស លោកចៅអធិការក៏ទទួលពាក្យថាចំរើនពរ ពេលនេះក្មេងវាមិននៅជុំគ្នា អាខ្លះវាទៅផ្ទះអាខ្លះទៅតាមអ្នកយើងទៅសូត្រមន្ត បើដូច្នេះចាំវាមកជុំកាលណា អាចក្តីនឹងជេរវាយហាមវាឲ្យ អើញោមអើយ ធ្វើម្តេចអាកូនក្មេងនេះ អាចក្តីក៏បានហាមប្រាមដែរវាកោតខ្លាចតែនៅមុខដល់កំបាំងមុខទៅវានាំគ្នាទៅប្រព្រឹត្តផ្លូវពាលដដែល ។ តាភោគបានឮចៅអធិការទទួលពាក្យខ្លួនថានឹងជេរវាយកូនសិស្សឲ្យដូច្នោះក៏សប្បាយចិត្តបាត់ក្តីទោសោ ទើបរីករាយនិយាយអំពីការឯទៀតៗ ។ ឯលោកចៅអធិការក៏នាំនិយាយពីហេតុនេះហេតុនោះតម្រូវចិត្តតាភោគៗ ក៏តាំងផឹកទឹកតែ និយាយលេងជាមួយនឹងលោកចៅអធិការនោះជាយូរលង់ ។



ឯកូនក្មេងវត្តកាលដល់ពេលវាមកជុំគ្នា បានឃើញតាភោគមកទូលលោកឲ្យជេរវាយវាដូច្នោះវាក៏ជំនុំគ្នា ពួកយើងទៅបេះផ្លែភ្ញៀវតាភោគពីព្រឹកមិញ ឥឡូវគាត់មកពិតលោកគ្រូឲ្យវាយពួកយើងហើយ លោកគ្រូថាចាំពួកយើងមកជុំគ្នាកាលណា លោកនឹងវាយឲ្យគាត់ប្រាកដហើយ អើរ៉ុយកនយើង ឥឡូវតាភោគគាត់បជាប់ដៃនិយាយប្រាជ្ញព្រោកនឹងលោកគ្រូយើង ផ្ទះគាត់ស្ងាត់គ្មាននរណានៅទេ បើដូច្នេះកនយើង គួរទៅបេះផ្លែឈើគាត់ស៊ីឲ្យផ្អែតទាំងអស់គ្នាសិន គង់តែយើងត្រូវរំពាត់ដដែលទេ យើងបេះមុន ក៏ដូចជាបេះក្រោយដែរ ពួកក្មេងនិយាយប្រឹក្សាយល់ព្រមគ្នាហើយ ទើបនាំគ្នាហែករបង កន្លងចូលទៅដល់ដើមភ្ញៀវហើយឡើងបេះស៊ីខ្លះ បេះស្ពាយយកទៅវត្តខ្លះ ខ្លះថ្ពក់ ខ្លះកាវ ខ្លះអង្រួនឲ្យគ្នាវារើសរេច រើសស៊ីតាមចិត្តទីទៃៗ លុះល្ងាចទើបវានាំគ្នាទៅវត្ត ។ ឯតាភោគ លុះដល់ពេលល្ងាចហើយ ក៏ថ្វាយបង្គំលាលោកចៅអធិការវិលទៅគេហស្ថាន បានឃើញសំបកភ្ញៀវសំបកដូងនឹងផ្លែចាស់ខ្ចីជ្រុះខ្ចាំនៅខាងផ្ទះខ្លួនដូច្នោះ ក៏រឹងតែខឹងស្តាយរបស់ខ្លួនក្រៃពេក កើតក្តៅក្រហាយចិត្តដ្បិតខ្លួននៅនិយាយលេងហួសការ គ្មាននរណានៅរក្សាផ្ទះ

រក្សាដំណាំផ្លួសខ្លួន ជាទីឱកាសឲ្យអាក្មេងវត្តវាមកបេះបោច
បុកបែនលើសលែងកាលមុនៗ នឹងទៅពិតលោកឲ្យជេរវាយ
ម្ដងទៀតក៏ផុតកាល គឺកាលមុនបានទៅពិតដល់លោកហើយ
លោកនៅមិនទាន់បានជេរវាយប្រដៅឲ្យឯងផង តាភោគគិត
រកផ្លូវធ្វើក្មេងពុំបាន ក៏រឹងរំខានក្ដៅចិត្តក្រៃពេកហោង ៗ

រឿងនេះបានគតិដល់បុគ្គលអ្នកនិយាយច្រើនភ្លើនចិត្តមិនគិត
នៅក្នុងប្រយោជន៍របស់ខ្លួន ចុះក្បួនពាក្យលោកថា "កោៗ
សឹកតែមាត់ត្រដោក ផ្អែតឯមាត់ក្របី ពោះគោឯនោះ" ៗ

តាអើយតាភោគ និយាយប្រាជ្ញព្រោក នឹងលោកសង្គ្រាជ
មិនឈប់បង្អង់ ពីត្រង់ដល់ល្ងាច អាក្មេងឡើងរាជ ពព្រេចដំណាំ ៗ
លុះល្ងាចទៅផ្ទះ ស្រាប់ឃើញរង្គះ ផ្កាផ្លែជ្រុះខ្ទាំ កើតក្ដៅក្រ
ហាយ សោកស្ដាយដំណាំ នេះគឺផលកម្ម និយាយមិនព្រាត ៗ

**ចប់តម្រានិយាយច្រើនចំរើនចោរ ជាគតិទី៤២។**

## រឿងចៅខ្ញុំគេសំឡាប់មាន់រងាវយាម

មានចៅម្នាក់នៅជាខ្ញុំគេនាយប្រើឲ្យធ្វើការបំរើនៅក្នុង
ផ្ទះជាប្រក្រតី ឯនាយនោះមានចិញ្ចឹមមាន់ចែឈ្មោលមួយសម្រា
ប់ឲ្យរងាវយាមរាល់ៗថ្ងៃ តែដល់ពេលមាន់នោះរងាវឡើង



កាលណាហើយ គេតែងដាស់ចៅនោះប្រើឲ្យទៅធ្វើការទាំង
ឡាយ មានរែកទឹកស្រោចដំណាំជាដើម ៗ

ឯចៅនោះបានក្ដីលំបាកដោយការងារនាយមានកំណត់មាន់
រងាវពេលក្រោកចាកនិទ្រា ទោះខ្លួនងុយដោកចង់ដេកវិញយ៉ា
ងណាៗ ក៏ពុំបានចៅនោះមានក្ដីរំខាន ទើបមកគិតថាអញខាន
ដេកខានពួនសព្វថ្ងៃនេះ ពីព្រោះតែមាន់យាមនេះឯង បានជា
នាយដាស់ឲ្យក្រោកទៅធ្វើការ ខានដេកក្នុងវេលានិទ្រាស្រួល
បើនឹងទុកមាន់យាមឲ្យវារងាវយ៉ាងនេះតទៅអញឃើញជាពិ
បាកណាស់ ព្រោះនាយគាត់ប្រើក្នុង កាលមាន់នេះវារងាវបើ
ដូច្នោះមានតែអញចាប់មាន់នេះយកទៅសម្លាប់ចោលឲ្យបាត់
កុំឲ្យនាយគាត់អាងមាន់យាមនេះជាសញ្ញា ទើបការអញបាន
ស្រាលបានដេកលក់សុខសប្បាយទៅហោង គិតហើយចៅនោះ
លួចចាប់មាន់យាមនោះបាន ហើយយកទៅកំពង់ទឹកតាំងបោក
ប្រហារមាន់នោះស្លាប់ ហើយបោះចោលសាកសពមាន់នោះទៅ
ក្នុងស្ទឹង បិទការណ៍នោះមិនឲ្យនាយដឹងឮឡើយ ហើយរែកទឹក
វិលមកផ្ទះវិញហោង ៗ

ឯនាយនោះ កាលពីដើមបានមាន់យាមជាកំណត់នឹងដាស់ខ្ញុំឲ្យ

ទៅធ្វើការផ្សេងៗ ចាប់ដើមពីថ្ងៃឥតមាន់យាមនោះមក គាត់ចង់ដាស់ចៅខ្ញុំឲ្យក្រោកទៅធ្វើការក្នុងវេលាណាៗក៏បាន ស្រេចនឹងគាត់ត្រូវការវេលាណា ក៏ដាស់ប្រើក្នុងវេលានោះទៅ ឥតពេលដូចកាលមុនៗនោះឡើយ ។

ឯចៅនោះលុះត្រូវនាយប្រើឥតពេល កើតក្តីពិបាកលើសមុនទៅទៀត ក៏មកគិតស្តាយមាន់យាមនោះវិញថា កាលពីដើមគេប្រើអញដោយពេលមាន់រងាវ គឺតែដល់ពេលមាន់រងាវរួចហើយ នាយគាត់ដាស់ឯងឲ្យក្រោកទៅធ្វើការ ឯងគិតថាកំពុងដេកលក់ស្រួលដល់អាមាន់វារងាវ នាយដាស់ឯងឲ្យទៅប្រកបការ ឃើញថាទោសខានដេកនោះកើតអំពីមាន់ជាប្រាកដ ហេតុនោះបានជាឯងចាប់វាយកទៅប្រហារបង់ នឹកថានឹងបានសេចក្តីសុខសប្បាយខ្លះដល់ឥឡូវឥតពីមាន់យាមទៅ មានវិងវិតតែប្រើឯងលើសប្រមាណ គឺពុំមានពេលវេលាឡើយគាត់ចង់ប្រើវេលាណា ក៏ប្រើទៅតាមចិត្តជាម្តង ឱអញអើយដែលអញវាយមាន់ចោលនោះ ខុសប្រាកដទៅហើយ បើទុកមាន់នៅគ្រាន់បើជាងនេះព្រោះគេប្រើមានពេលមានកាលវេលាខ្លះចៅនោះគិតឃើញដូច្នោះក៏កើតក្តៅក្រហាយពុំសប្បាយហោង ។



រឿងនេះបានគតិដល់បុគ្គលអ្នកផ្លាស់កន្លែងស្វែងរកក្តីសុខដល់បានទុក្ខក៏ក្តៅក្រហាយសោកស្តាយកន្លែងចាស់វិញ ។

កើតមកជាទាសាទាសីគេហើយ នឹងគិតថានាយគេប្រើអញឆ្នាំនេះពិបាកតឹងណាស់ ដល់ឆ្នាំមុខៗយ៉ាងជាធូរជាងនេះទេដឹង ការគិតគ្នេរយ៉ាងនោះមិនត្រូវទេ វិស័យខ្លួនជាខ្ញុំគេហើយ នឹងស្វែងរកក្តីទំនេរក្តីសុខឯណាមាន គួរគិតទៅចុះ ។

ខ្ញុំអើយខ្ញុំគេ គិតរកទំនេរ គ្មានទេណ៎ាបា តែផ្លាស់កន្លែងរកស្វែងសុខា ក្រែងដូចតម្រា ចៅវាយមាន់យាម ។ មួយហត្ថជាន់មុន ជាន់ក្រោយទ្វេគុណ លើសមុនដប់ព្យាម ដៃអើយកុំកែ គង់ផ្លែរាល់ម្រាម ធ្វើនេះរួចភ្លាម ធ្វើនោះតទៅ ។

មួយទៀតអ្នកខ្លះបានកន្លែងកំណាចហើយ គិតផ្លាស់កន្លែងឲ្យធូរជាងមុនវិញ ចួនទៅប្រទះលើកន្លែងកាឡកណ្ណីកំណាចលើសមុនក៏មាន ដូចនិទាននាងនារីម្នាក់ ជាធីតាអ្នកមានត្រកូល នាងនោះបានប្តីអ្នកត្រកូលស្មើគ្នា តែចៅប្តីនោះជក់អាភៀនញៀនពេញកំឡាំង តាំងតែពីបានគ្នាមក ចៅប្តីបំផ្លាញទ្រព្យសម្បត្តិអស់ជាច្រើន ដោយលួចទិញអាភៀនជក់ ។

នាងជាភរិយាបានក្តីទុក្ខរំខានខ្លាំង ក៏គិតថាស្វាមីអញនេះ

បំផ្លាញទ្រព្យសម្បត្តិវិនាសអស់ជាម្ដងនឹងគិតឲ្យប្ដីលែងជក់អាភៀន ក៏គិតពុំសម្រេចទៅបានបើដូច្នេះគួរនិយាយនឹងគាត់ឲ្យផឹកសុរាវិញចុះ ព្រោះសុរាថោកជាងអាភៀន បើគាត់ជាប់សុរាហើយឃើញជាណាយអាភៀននោះមិនខានឡើយ ។

នាងនោះគិតដូច្នោះហើយ បានឱកាសក៏និយាយលួងលោមចៅប្ដីនោះថា អ្នកអើយសូមមេត្ដាកូនប្រពន្ធម្ដងចុះ បើអ្នកកាន់ល្បែងអាភៀនតែយ៉ាងនេះហើយ កូនប្រពន្ធនឹងធន់រកប្រាក់កាសចិញ្ចឹមគ្នាពុំបានទេ ព្រោះអាភៀនសព្វថ្ងៃនេះថ្លៃពេកណាស់មិនឈ្នះនឹងរកប្រាក់ទិញឲ្យជក់ទេ ។

បើដូច្នេះ ចូរអ្នកផឹកសុរាកែខ្លួនវិញចុះព្រោះសុរាថោកជាងអាភៀន គ្រាន់តែ ២ ៣លុយទៅក៏ផឹកឆ្អែតបានរាល់ល្ងាចទៅហើយ ។

ឯចៅប្ដីបានឮប្រពន្ធថាដូច្នោះក៏ព្រមតាម ទើបឲ្យប្រពន្ធទិញសុរាមកឲ្យផឹក ដើម្បីបន្ទូរផ្លូវអាភៀននោះ ។ ឯនាងប្រពន្ធតែងទៅលក់បន្លែឬផ្លែឈើនៅផ្សារ និមិត្តតែអស់កាលណាក៏ទិញសុរាដាក់ដបយកមកផ្ញើរចៅប្ដីរាល់ៗថ្ងៃរៀងទៅ ។

ឯចៅប្ដីបានផឹកសុរាជាប់ហើយ ក៏តាំងទ្វេឡើងដល់ថ្ងៃ១កាក់



ទើបឆ្អែត នាងប្រពន្ធក៏ចេះតែស៊ូរកឲ្យផឹកបានរាល់ថ្ងៃ ។

ចៅប្ដីកើតជាអ្នកប្រមឹក ផឹកតែឯងមិនសប្បាយទើបត្រាច់ទៅគប់អ្នកប្រមឹកឯទៀតយកគ្នាជាភឿនផឹកដើរផឹកស៊ីតាមតៀមចិនតាមរានផ្សារ តែស្រវឹងកាលណា មកផ្ទះបង្កហេតុឈ្លោះប្រកែកបញ្ចោរប្រពន្ធជួនកាលស្រវឹងខឹងវាយចានវាយឆ្នាំង បោកប្រាសតុថាស ដាល់តប់កូនប្រពន្ធក៏មាន ជួនណាដេរគេឯងដែលមិនមែនជាញាតិ កើតវិវាទឈ្លោះប្រកែកបែកកើតជាក្ដីត្រូវពិន័យបង់ប្រាក់ ដោយចាញ់ក្ដីគេក៏មានជួនណាទៅស្រវឹងតាមផ្លា អួតអាងក្អេងក្អាងដាក់ចៅនាទីៗ អត់មិនបានក៏វាយដំធាក់ប្រានចាប់យកខ្លួនទៅដាក់គុកកើតបង់ប្រាក់លោះខ្លួនក៏មាន ។

ក្ដីអាក្រក់នៃចៅប្រមឹកនោះ ឮប្រាកដសុះសាយទួទៅ ឯនាងប្រពន្ធធន់ពុំបាននឹងក្ដីរំខានចៅប្ដីធ្វើទុក្ខច្រើនប្រការណាស់ទើបមកគិតថា កាលជក់អាភៀននោះ គឺបង់តែប្រាក់ថ្ងៃទិញអាភៀនចំណែកមួយ តែជក់ឆ្អែតហើយមកផ្ទះជួយចាប់កូនចាប់ចៅឬជួយធ្វើការឯទៀតៗបានខ្លះ ដូចជាគ្រាន់បើជាងផឹកសុរា ឯសុរានេះចាប់ដើមពីចេះផឹកមកពុំបានការអ្វីមួយយ៉ាងសោះ ចេះតែ

ដេរវាយកូនប្រពន្ធ បោកប្រាស់ចោលចានចោលឆ្នាំង បំផ្លាញ
ទ្រព្យសម្បត្តិខូចជាច្រើន ៗ

ឱអញអើយគិតខុសទៅហើយ ពីដើមគិតថាអាភៀនហើយ
ជាវត្ថុកំណាចកាចខ្លាំងក្លា គិតយកសុរាមកបន្ថោឲ្យអន់ ឥទ្ធិវា
មិនគ្រាន់ ត្រឡប់អាអន់ទ្វេឡើងជាឯកប្លែកលើសអាភៀន
នោះទៅទៀត មែនពិត រីឯអាភៀនសុរានឹងល្បែងភ្នាល់គ្នា
ទាំងឡាយនោះតែកើតមានកំលាំងក្លាហានហើយ ក៏ដូចគ្នាទាំង
អស់នឹងទៅនិន្ទាឬ សរសើរថាអាភៀនជារបស់គ្រាន់បើជាង
សុរា ឬថាសុរាគ្រាន់បើជាងអាភៀន ឬថាអំពើល្បែងបៀប៉ោ
គ្រាន់បើជាងសុរា ជាងអាភៀនវិញយ៉ាងនេះពុំបាន ព្រោះរប
ស់ទាំងបីនោះមានកំលាំងផ្សាយទៅដូចគ្នា តែមាននៅលើសំ
បុកណាហើយ ក៏អាចធ្វើសំបុកនោះឲ្យវិនាស បាននូវក្តីក្តៅក្រ
ហាយហោង ៗ មួយទៀតជំនុំរបស់៣ យ៉ាងនេះរបស់ឯណាមួយ
មាននៅលើសំបុកណាហើយ សំបុកនោះសឹងស្រែកសឹងពោល
ថា ធ្ងន់ណាស់ ពិបាកណាស់លើសរបស់ឯទៀតៗ ឯរបស់ឯង
ទៀតៗនោះដូចជាគ្រាន់បើជាងរបស់នេះ ៗ

ពាក្យពោលយ៉ាងនេះ មានឧបមាដូចបុគ្គលអ្នកកើតរោគធ្ងន់



កាលណាឈឺខ្លាំងក៏តាំងស្រែកថ្ងូរថារោគឈឺក្បាលនេះឈឺលើស
អវយវៈឯទៀតៗ បើទៅឈឺដៃឬជើងឬក៏ពោះវិញ នោះដូច
ជាគ្រាន់បើជាងឈឺក្បាលនោះ ៗ

ដល់មានរោគចុកពោះយ៉ាងខ្លាំងឡើង ក៏ស្រែកថ្ងូរពោលថា
រោគឈឺពោះនេះឈឺលើសទីឯទៀតៗ ដល់ឈឺធ្មេញយ៉ាងខ្លាំង
ឬកើតដំនួចពិលនៅម្រាមដៃយ៉ាងខ្លាំង ក៏ប៉ះននៀលស្រែក
ថ្ងូរពោលថា ឈឺលើសអវយវៈឯទៀតៗ ពាក្យអ្នកឈឺពោល
យ៉ាងនេះតែរោគយ៉ាងមធ្យមៗ បើដល់រោគយ៉ាងខ្លាំងយ៉ាងស
ហ័សនោះហើយ មិនថាឈឺនៅអវយវៈណាទេសឹងបានក្តីទុក្ខវេទ
នាដូចគ្នាទាំងអស់ ស្រួលតែមិនឈឺនោះឯងទើបសុខ ទើប
សប្បាយបានមានឧបមេយ្យដូចសំបុកណា ដែលគេមិនមានរោ
គអាភៀន រោគសុរា រោគល្បែងបៀប៉ោជាដើមនោះឯង
ទើបសុខ ទើបសប្បាយបានបានហោង អ្នកមានបញ្ញាគួរចូល
ចិត្តចុះ ៗ

**ចប់តម្រាកន្លែងកំណាចចាស់គិតផ្លាស់កន្លែងកំណាចថ្មីជាគតិទី ៤៣។**

# រឿងបុរសប្តីប្រពន្ធចិញ្ចឹមសត្វស្កា

មានចៅប្តីប្រពន្ធពីរនាក់ជាជាតិអ្នកចំការ បានចិញ្ចឹមសត្វលា១ ទុកប្រើប្រាស់ការក្នុងផ្ទះតាមភាពនៃខ្លួនជាអ្នកមានកូនខ្ចី បីទ្រពរក្សាស្កានោះពុំឲ្យមានហ្មងសៅឡើយ ។ ថ្ងៃមួយដាក់កូនឲ្យដេកក្នុងអង្រឹងហើយទុកស្កាឲ្យនៅមើលរក្សាផ្ទះនឹងកូនអាត្មាឯងពីរនាក់នាំគ្នាទៅជំរះស្មៅដំណាំឯខាងកន្ទ្រៃផ្ទះក្រោយនោះ មានអាសិរពិសពស់វែកមួយ លូនចូលទៅក្នុងផ្ទះបានធុំក្លិនទឹកដោះនៅមាត់ទារក ក៏លូនចូលទៅក្នុងអង្រឹងហើយចឹកទារកនោះៗ ក៏ស្រែកយំដោយសម្លេងខ្លាំងៗ ។

ឯស្កានោះលុះបានឮសម្លេងក្មេងយំដូច្នោះ ក៏ស្ទុះឡើងទៅលើអង្រឹង បានយល់ពស់វែកចឹកកូននាយ ក៏ខឹងនឹងពស់ក្រៃពេកទើបតយុទ្ធប្រខាំនឹងពស់ៗស្ទុះកំលាំងស្កាមិនបាន ស្កាក៏ខាំពស់នោះដល់នូវក្តីស្លាប់ ហើយខាំអូសទាញយកសាកសពពស់ទៅដាក់ញាត់ទុកនៅក្រោមជើងម៉ា ។

ឯទារកនោះធន់នឹងពិលពស់ពុំបាន ក៏ដល់នូវមរណកាលក្នុងអង្រឹងនោះឯង ។

ថ្លែងឯចៅប្តីនឹងប្រពន្ធនោះ លុះដល់ពេលក៏នាំគ្នាវិលមកផ្ទះ



ឯស្កាឃើញម្ចាស់មកដល់ នឹងនិយាយប្រាប់រឿងពស់វាខាំកូននោះពុំបានដោយជាតិជាសត្វក៏ខំរែតរត់ទៅរត់មក ធ្វើអាការក៏ដូចជាប្រាប់រឿងដល់នាយ ឯនាយក៏ពុំមានសេចក្តីសង្ស័យអ្វី លុះនាងប្រពន្ធទៅលើកកូន ដើម្បីនឹងផ្តុតទឹក ក៏ស្រាប់តែឃើញកាលកូនជាំដាំ ស្លាប់រឹងក្រញ៉ាងនៅក្នុងអង្រឹងនោះឯងនាងក៏ស្រែកទួញឡើង ចៅប្តីភិតភ័យស្ទុះទៅសួរប្រពន្ធៗប្រាប់ថា កូនយើងស្លាប់ហើយ មិនដឹងថាស្លាប់ដោយហេតុអ្វីទេ ចៅប្តីក៏តក់ស្លុតយំសោកស្តាយកូន ហើយសង្កេតមើលស្លាកស្នាមកូនទៅឃើញមុខស្នាមចង្កូមធ្មេញពស់នៅភ្លៅកូន ក៏នាំគ្នាគិតថាស្កានោះវាខាំកូនខ្លួនប្រាកដពិត មិនគិតពិចារណាឲ្យវែងឆ្ងាយ កើតខឹងនឹងស្កា ទោះប្រហារស្កានោះដល់នូវមរណភាព ហើយទើយកក្តារដើម្បីធ្វើជាហិបដាក់ខ្មោចកូនយកទៅកប់ លុះទើសំពត់អាវនៅក្រោមជើងម៉ា ក៏បានយល់សាសពពស់នៅនោះបានឃើញស្នាមមាត់ស្កាខាំពស់ជាប្រាកដ ក៏ដឹងថាកូនខ្លួនស្លាប់ដោយពស់ចឹកទេ ស្កាជាសត្វយកអាសានាយ ស៊ូខាំពស់ដរាបដល់ពស់ស្លាប់ហើយទាញយកមកទុកក្រោមជើងម៉ានេះ ជនទាំងពីរកាលណាបើយល់ការណ៍ដូច្នោះហើយ ក៏កើតសោកសៅក្តៅក្រហាយចិត្តនឹក

អណិតដល់កូនផងដល់ស្កាផង កើតស្តាយស្កាពន់ពេកណាស់ដោយខ្លួនឥតពិចារណាទៅប្រហារសត្វឥតទោស ឯណាកូនក៏ស្លាប់ស្កាក៏ស្លាប់ផង ក្តីទុក្ខរឹងរឹតតែច្រើនលើសលន់ផុតនឹងពណ៌នាបាននូវក្តីសោកស្តាយទាំង២ ផ្លូវហោង ។

រឿងនេះ បានគតិដល់បុគ្គលអ្នកខឹងហួសប្រមាណ ឥតបញ្ញាពិចារណាឲ្យដុំរិញបាន បុគ្គលណាគិតអ្វីប្រញាប់ មិនទេវិះឲ្យអស់ជើង បន្ទាន់ធ្វើការនោះទៅដោយចិត្តក្តៅ បុគ្គលនោះគង់នឹងលុះផ្លូវខុស បានក្តីក្តៅក្រហាយជាងក្រោយ ដូចចៅប្តីប្រពន្ធវាយស្កានោះឯង ។

មួយទៀត បុគ្គលធ្វើការប្រញាប់បានក្តីក្តៅចិត្តក្នុងកាលក្រោយនោះ ដូចបទបាលីក្នុងគម្ពីរលោកនីតិថា៖

មា ច វេគេន កិច្ចានិ
ការេសិ ការាបេសិ
សហសា ការិតំ កម្មំ
មន្ទោ ចច្ឆានុតប្បតិ។

ប្រែថា "ជនធ្វើការប្រញាប់ដោយខ្លួនឯង ឬប្រើគេបាត់



ចែងឲ្យធ្វើច្បាស់ អំពើដែលធ្វើដោយសហ័សខ្លាំណាស់គង់ក្តៅក្រហាយក្រោយ" ។

**ចប់គតិទី ៤៤ ។**

## រឿងបុរសចិញ្ចឹមខ្លាឃ្មុំ

មានចៅម្នាក់ចិញ្ចឹមខ្លាឃ្មុំតាំងពីតូចដល់ធំប្រើការឲ្យខាំពាំនាំអ្វីៗ បានគ្រប់យ៉ាង មានកាលថ្ងៃ១ចៅនោះនាំខ្លាឃ្មុំទៅព្រៃលុះទៅដល់ដើមឈើធំមានម្លប់ត្រសុំសាខា ត្រូវខ្យល់ផាត់រំភើយល្ហើយស្រួល ចៅនោះក៏ក្រាលសំពត់ដេកទំហើយខ្យល់ បានផ្តាំខ្លាឃ្មុំឲ្យនៅយំរក្សាខ្លួន ហើយថាឲ្យមើលសត្វពាទ្យ្រមឹគយង់ឃ្នងនានា ក្រែងវាចូលមកបិន្ទាយាយីខ្លួនឲ្យដេញកំចាត់ពួកសត្វនោះៗ ចេញផ្តាំហើយចៅនោះ ក៏ដេកលក់ទៅហោង ។

ឯខ្លាឃ្មុំនៅយំរក្សាការអន្តរាយនាយពុំបានក្រោកទៅឯណាចាំគន់មើលអន្តរាយពុំឃើញមានអ្វីមានតែរុយមួយ វាហើរមកទំនៅមុខនៅចុងច្រមុះនាយរឿយៗ ខ្លាឃ្មុំជាសត្វស្លូតត្រង់នឹងម្ចាស់ តែគ្មានបញ្ញានឹងពិចារណាឲ្យដឹងថាអន្តរាយតូចធំយ៉ាងម៉េចៗ ឃើញតែរុយក៏ទះផាត់ចេញអំពីមុខម្ចាស់ ឯរុយសោតជាសត្វហាមពុំមាន ជាសត្វរហ័សហើររហ័សទំរឿយៗ ខ្លាំឃ្មុំ..

បោកផាត់មិនឈ្នះក៏ទោសោ ខឹងនឹងរុយនោះលុះរុយវាទំនៅប្រមុះម្ចាស់ក៏ចាប់បានដុំថ្មមួយដុំ បោលទៅលើប្រមុះម្ចាស់ដើម្បីសម្លាប់រុយៗជាសត្វរហ័សហើរគេចេញផុតទៅ ឯចៅនាយនោះលុះត្រូវដុំថ្ម ប្រមុះបែកចេញឈាមភ្ញាក់ស្ទុះក្រោកឡើងយកដៃខ្ទប់មុខបានក្ដីទុក្ខវេទនា ឈឺចាប់ពន់ពេក ក៏ខឹងនឹងខ្លាឃ្មុំចាប់ដំបងវាយ ២,៣ ដំបងហើយនាំខ្លាឃ្មុំវិលទៅផ្ទះ រកថ្នាំលាបដំបៅបានក្ដីក្ដៅចិត្តកើតទុក្ខហោងៗ

រឿងនេះបានគតិដល់បុគ្គលអ្នកធ្វេសសតិបញ្ញាទៅទុកចិត្តសត្តិរច្ឆានមានតែសន្ដានស្លូតត្រង់ នឹងបានមានប្រាជ្ញាស្គាល់ទោសទុក ដូចមនុស្សយើងនេះក៏ឥតអង្គីមាន គួរគិតពិចារណាទៅទៀតចុះៗ

**ចប់តម្រាទុកចិត្តសត្តិរច្ឆានជាគតិទី ៤៥។**

## រឿងខ្លាឃ្មុំនឹងដើមពង្រ

មានខ្លាឃ្មុំទៅដេកក្រោមដើមពង្រ១ លុះដេកលក់បន្តិចទៅផ្លែពង្របាក់ធ្លាក់មកត្រូវក្បាលខ្លាឃ្មុំនោះ ខ្លាឃ្មុំក៏ភ្ញាក់ឡើងម្នីម្នា បានក្ដីឈឺក្បាលពន់ពេកណាស់ ក៏ដើរចេញចាកទីនោះហើយនឹងខឹងដើមពង្រ ចងអាឃាដថា អាដើមពង្រនេះអញ



កំពុងដេកលក់សុខសប្បាយវាទំលាក់ផ្លែមកមកលើក្បាលអញបានក្ដីទុក្ខវេទនាមានសភាពយ៉ាងនេះ អើបើអញបានឱកាសណា អញនឹងរំលំរលឹងវាឲ្យអស់ពូជជាម្ដង ខ្លាឃ្មុំចងគំនុំចងពៀរនឹងដើមពង្រដូច្នេះហើយ ក៏ត្រាច់តាមដើងព្រៃទៅកាន់ទីតាមក្ដីប្រាថ្នាៗ គ្រាកាលនោះមានអ្នករទេះម្នាក់បររទេះមកត្រង់ទីនោះ ចួនជាភ្លៅរទេះបាក់ក៏ឈប់ ហើយកាន់ពូថៅដើរចូលព្រៃ ដើម្បីនឹងកាប់ឈើធ្វើភ្លៅរទេះ លុះដើរៗទៅបានជួបខ្លាឃ្មុំកណ្ដាលព្រៃ ខ្លាឃ្មុំក៏សួរថា អ្នកឯងដើររកអ្វី ចៅនោះក៏ប្រាប់ថា យើងដើររកកាប់ឈើធ្វើភ្លៅរទេះ ខ្លាឃ្មុំបានឮដូច្នោះបានឱកាស ទើបប្រាប់ទៅថាឈើសម្រាប់ធ្វើភ្លៅរទេះគ្មានឈើអ្វីឲ្យជាប់ស្វិតដូចដើមពង្រទេ ចូរអ្នកឯងទៅកាប់ដើមពង្រឯនោះចុះ ចំពោះជាធ្វើភ្លៅរទេះជាប់ល្អហើយ ថាហើយក៏នាំផ្លូវចៅនោះទៅកាន់ដើមពង្រហើយដើរចេញអំពីនោះទៅហោងៗ

ឯអ្នករទេះក៏ចូលទៅកាប់ដើមពង្រនោះ តាមពាក្យខ្លាឃ្មុំប្រាប់ ឯដើមពង្រនោះជាលំនៅនៃរុក្ខទេវតាៗ កាលបើឃើញមនុស្សកាប់លំនៅខ្លួនដូច្នោះក៏ចេញមកសួរថា អ្នកឯង

កាប់ដើមពង្រងនេះតើដើម្បីការអ្វី ៗ

ចៅនោះប្រាប់ថា យកទៅធ្វើភ្លៅរទេះដ្បិតខ្លាឃ្មុំបានប្រាប់ថាឈើនេះជាប់ល្អណាស់ រុក្ខទេវតាដឹងថាខ្លាឃ្មុំចង់គំនុំនឹងដើមពង្រង ព្រោះតែមែកពុកបាក់ធ្លាក់លើក្បាលវាដូច្នោះ ក៏ចងពៀរតបតខ្លាឃ្មុំវិញទើបតថា អើអ្នក ឯដើមពង្រងធ្វើភ្លៅរទេះនោះជាប់មែន តែស្រួយឆាប់បាក់ទេអ្នកបើបានខ្លាញ់ខ្លាឃ្មុំមកលាបនោះ ទើបស្វិតជាប់ល្អបរទៅសប្បាយ បើដូច្នេះចូរអ្នកឯង ទៅសម្លាប់ខ្លាឃ្មុំយកខ្លាញ់វាទុកលាបភ្លៅរទេះអ្នកទៅហោង ៗ ឯអ្នករទេះបានឮដូច្នេះក៏ចេញចាកទីម្ទីម្នាត្រាច់ទៅតាមខ្លាឃ្មុំនោះលុះទៅទាន់ហើយក៏ប្រហារខ្លាឃ្មុំនោះដោយពូថៅធំ ខ្លាឃ្មុំក៏ដល់នូវក្ដីស្លាប់ក្នុងកាលនោះឯង ដូចខ្លាឃ្មុំស្អប់ដើមពង្រងដែលសំដែងទុកមកនេះ ប្រាជ្ញគប្បីដឹងហោង ៗ

ខ្លាអើយខ្លាឃ្មុំ ចងចិត្តគំនុំ នឹងដើមពង្រង ព្រោះមែកត្រូវក្បាល បណ្ដាលតាំងគ អាឃាដបង្ក ជាពៀរនឹងគ្នា ៗ ខឹងបាញ់ព្រោះស្អប់ បាញ់ប្រែត្រឡប់ មកត្រូវអាត្មា អំពើចងពៀរពំនៀវលោកថា មិនស្រាយកាលណា មិនត្រានឹងផុត ៗ

**ចប់តម្រាស្អប់កុំឲ្យបាញ់ ជាគតិទី ៤៦។**



## រឿងសត្វគ្រលេងគ្រលោងនិងស្វា

មានសត្វគ្រលេងគ្រោងញីឈ្មោលមួយគូ ធ្វើសំបុកភ្ញាស់កូននៅប្រគាបមែកឈើមួយ កាលនោះមានពានរមួយ ត្រូវភ្លៀងអុរដោកដាំ កើតក្ដីរងាខ្លាំងក៏លោតទៅជ្រកក្រោម សំបុកគ្រលេងគ្រោងៗ ឃើញស្វាជ្រកដូច្នោះ ក៏និយាយជាពាក្យឱវាទថាឪពានរអើយ រូបអ្នកឯងមានដៃមានជើងដូចជាមនុស្សហេតុអ្វីអ្នកមិនធ្វើផ្ទះធ្វើសំបុកជាទីអាស្រ័យនៅ ៗ

ឯស្វាតបទៅថា យើងមានដៃជើងដូចមនុស្សក៏ពិតហើយតែយើងគ្មានប្រាជ្ញាឈ្លាសក្នុងការធ្វើផ្ទះធ្វើសំបុកដូចមនុស្សទេហេតុនោះបានជាយើងឥតផ្ទះឥតសំបុកជ្រកនៅយ៉ាងនេះ គឺយើងធ្វើមិនកើត ៗ ឯគ្រលេងគ្រោងក៏ឆ្លើយឡើងថា សព្វបើការធ្វើសំបុកចាំមានបញ្ញាវិសេសនឹងរចនាអ្វី តែពួកសកុណបក្សីយ៉ាងចាបលលកឬរូបខ្ញុំឯងនេះ ក៏អាចធ្វើតាមភាពជ្រកភ្លៀងទៅបាន ពួកសកុណជាតិមានតែចំពុះមួយនឹងមានដៃជើងដូចបងពានរឯងក៏ទេ ម្ដេចគេធ្វើជ្រកអាស្រ័យបាន គួរបងឯងគិតមើលទៅចុះ ក៏វិស័យសត្វទាំងឡាយដែលកើតមកនេះ តោងមានទីមានលំនៅដាកកូនដាក់ប្រពន្ធ ដើម្បីជ្រកកោនឲ្យផុតអន្តរាយ

គឺភ្លៀងខ្យល់កំដៅថ្ងៃ ទើបបានក្ដីសុខក្ដីសប្បាយទៅបានទោះជាធ្វើផ្ទះល្អពុំបាន ក៏គ្រាន់តែយកមែកឈើស្លឹកឈើ បិទបាំងប្រគែងប្រគងទៅតាមភាពល្មមតែជ្រកអាស្រ័យការពារភ្លៀងផ្គរម្ដងៗ ឯនឹងទៅគិតថាចាំជ្រកកោនដោយសារគេ ឬចាំជ្រកដោយគុម្ពឈើគុម្ពព្រៃនោះជាការលំបាកកាយកូនប្រពន្ធណាស់ បងពានរឯងមានដៃមានជើងល្មមធ្វើបានហើយ គួរតែធ្វើទៅ អេះនឹងទៅគិតថាចាំមានបញ្ញាសឹមធ្វើនោះ បញ្ញាឯណានឹងមានមកជាថ្មីទៀត កំណើតនៃសត្វតិរិច្ឆានទាំងឡាយ សឹងមានចិត្តមានវិញ្ញាណចេះរកអាហារចិញ្ចឹមជីវិតដូចគ្នាទាំងអស់ នឹងបានចាំរកធ្វើស្រែធ្វើចំការដូចមនុស្សនោះក៏ទេ ម្ដេចគេឯទៀតៗ ដោយហោចទៅសូម្បីតែសត្វដង្កូវឬកណ្ដូបកណ្ដៀវ ក៏ចេះធ្វើសំបុកនៅបាន ត្រង់បងពានរឯងម្ដេចធ្វើពុំបាន សត្វឯទៀតនោះ តើនឹងមានបញ្ញាលើសបងឯងកាលណាគេក៏ឧស្សាហ៍ធ្វើទៅកើត ខ្ញុំយល់ថាបងឯងមិនធ្វើនោះព្រោះក្ដីខ្ជិលមួយនេះឯង ឯពាក្យបងឯងថាធ្វើមិនកើតព្រោះគ្មានបញ្ញាដូចមនុស្សនោះ ខ្ញុំឯងមិនយល់ផងទេបងពានរ ។ ឯស្វានោះ លុះឮក្រលេងក្រលោងថា ដូច្នោះ ក៏កើតក្ដីខ្មាសក្ដីទោសោខឹងនឹងពាក្យក្រលេង



គ្រលោងទម្លាក់ចោល អំពីប្រគាបមែកឈើអស់ជាម្ដងហើយក៏លោតទៅកាន់ដើមឈើឯទៀតហោង ។

រឿងនេះបានគតិដល់បុគ្គលអ្នកកោងឱតពាក្យឱវាទ គឺគេតឿនសតិឲ្យខ្លួនធ្វើលំនៅៗ ជាសុខរបស់ខ្លួនឯងត្រឡប់ថាខឹងនឹងគេវិញ ហើយបំផ្លាញលំនៅគេផង មួយទៀតមានអ្នកខ្លះនៅជិតគុម្ពស្បូវគុម្ពឬស្សីតែខ្ជិលមិនជួសជុលផ្ទះ បណ្ដោយឲ្យភ្លៀងលេចជញ្ជាំងធ្លុះរហែករហោកស៊ូជ្រកនៅ ត្រូវភ្លៀងត្រូវថ្ងៃក៏ទ្រាំនៅទៅ ដល់មានគេតឿនឲ្យជួសជុល ក៏ត្រឡប់ខឹងនឹងគេវិញ យ៉ាងនេះក៏មាន មួយទៀតមានអ្នកខ្លះខ្ជិលធ្វើផ្ទះនៅ ស៊ូទៅនៅដោយសារឆ្នៀងតាកផ្ទះគេ ស៊ូទ្រាំសុំដីម្ចាស់ផ្ទះដែលគេមិនគាប់ចិត្តចង់ឲ្យនៅនោះយ៉ាងនេះក៏មាន មួយទៀតមានអ្នកខ្លះនៅជិតខាងគេ មានដីទំនេរ ខ្ជិលមិនដាំដំណាំទុកអាស្រ័យតែដល់ពេលខ្លួនត្រូវការ ដូចយ៉ាងស្លឹកគ្រៃឬស្លឹកជីរជាដើមក៏ទៅសុំគេ ដល់សុំគេរឿយៗណាស់ម្ចាស់ដំណាំគេទញ់ទាល់ចិត្តមិនចង់ឲ្យ គេក៏ស្ដីថាម៉េចឯងមិនដាំស៊ីខ្លះ ចេះតែរកគេយ៉ាងនេះ គេបានដាស់តឿនឲ្យខ្លួនដាំដំណាំទុកជាប្រយោជន៍ខ្លួនឯង មិនដាំឡើយត្រឡប់ទៅខឹងនឹងគេ ទៅលួចកាប់គាស់

បំផ្លាញ់ដំណាំគេចោលបង់ ដូចយ៉ាងស្វាទៅរោចសម្រុកគ្រលេង គ្រលោងចោលនោះឯង គួរចូលចិត្តហោង ។

ស្វាអើយចៅស្វា ជាសត្វសាវា ខ្ជិលធ្វើសម្រុក តែភ្លៀងធ្លាក់ ត្រូវទ្រាំនៅកោនកុក រងរងក្តីទុក្ខ គ្រាអស់សម័យ ។ កូនចៅ ពិបាក រងាររងាក រងោកដោយព្រៃ ម្តេចស្វាមិនស្វះ ធ្វើផ្ទះអាស្រ័យ ហាលភ្លៀងហាលថ្ងៃ មិនខ្មាសបក្សី ។

**ចប់តម្រាកោងឱវាទ ជាគតិទី ៤៧។**

## រឿងពស់ក្បាលច្រើនកន្ទុយតែ១និងពស់ក្បាលតែ១ កន្ទុយច្រើន

**និទាននេះមានដំណាលក្នុងក្បួនបារាំងសែស**

មានពស់ពីរ ពស់មួយក្បាលច្រើន កន្ទុយតែ១ ពស់មួយទៀត មានកន្ទុយច្រើនតែក្បាលតែ១ ។ ពស់ទាំងពីរលូនមកជួបគ្នា ក៏និយាយអួតឫទ្ធិ អួតអំណាចទីទៃៗ ឯពស់ក្បាលច្រើនអួតថា "យើងមានក្បាលច្រើននេះ ជាការមានប្រយោជន៍ច្រើន គឺនឹង គិតការអ្វីៗ បានពិគ្រោះប្រឹក្សាយល់ព្រមគ្នា ទើបធ្វើការនោះ សម្រេចទៅបាន" ។ ឯពស់ក្បាល១ អួតថា "យើងមានក្បាលតែ



១ជាការមិនទាស់ទែង បើចង់លូនចូលចេញតាមច្រកចង្អៀត ក៏ចេញចូលបានងាយ កន្ទុយច្រើន យើងសម្រេចតាមក្បាល១មិន មានទើសទែងនឹងអ្វី នៃប្រស្តែងពស់ក្បាលច្រើន យើងនឹងលង ឫទ្ធិគ្នាក្នុងគ្រានេះ ឲ្យឃើញជារូបណាចេញចូលតាមចន្លោះ របងសួននេះបាន រូបណាចេញចូលពុំបានគង់ដឹងឫទ្ធិគ្នាជាប្រាកដ" ។ ពស់ក្បាល១ ថាហើយក៏លូនចូលទៅក្នុងចន្លោះរបង សម្របកន្ទុយតាមគ្នាចូលបានចេញបានឥតទើសទាល់នឹងអ្វីឡើយ ឯពស់ក្បាលច្រើនឃើញពស់ក្បាល១ លូនចូលចេញទៅ ដូច្នោះក៏លូនចូលទៅតាម តែទៅពុំរួចព្រោះទើសនឹងក្បាល ច្រើន ខំជ្រែកជែកចូលយ៉ាងណាៗ ក្តីក៏ចូលទៅពុំបានឡើយពស់ ក្បាលច្រើន ក៏កើតក្តីខ្មាសអៀននឹងពស់ក្បាល១ ចាញ់គេ ហើយ ទើបលូនវត់ទៅកាន់លំនៅខ្លួនវិញហោង ។

ពាក្យឃ្លោង៖ ពស់មួយក្បាលច្រើនចំរើនទាស់ ចូលមិនអស់ ចេញមិនអបសម្របគ្នា ពស់មួយកន្ទុយច្រើនទោះបែកវា អាសម្របស្របគ្នាចូលចេញងាយ ។

ពាក្យទំនៀមថា៖ វត្តមួយសង្ក្រាជពីរទើមិនស្អាត លោកធាតុ មួយមានអាទិត្យបី នគរមួយស្តេចច្រើនអធិបតី ប្រាជ្ញគប្បីដឹង

ដោយពាក្យឧបមា ។

ក្នុងគម្ពីរលោកនីតិថា៖

ពហវោ យត្ថ នេត្តារោ
សព្វេ បណ្ឌិតា មានិនោ
សព្វេ មហត្តមិច្ឆន្តិ
តេសំ កម្មំ វិនស្សតិ។

ប្រែថា អ្នកធំច្រើនប្រាជ្ញច្រើនក្នុងទីណា សឹងប្រាថ្នាចង់ធំទីទៃៗ ការងារដែលធ្វើនោះពុំប្រពៃ ចុះក្នុងន័យហីនជោគលោកវិនាស ។

មានអ្នកស្រុកនៅមាត់សមុទ្រមួយនាក់ បានទៅដងយកគីរូបដូចកំពីសមកធ្វើកាពិ លុះបានក៏ដាក់នឹងកញ្ជ្រែង ហើយយកទៅកញ្ច្រោលាងទឹកថ្លុកមួយនៅខាងផ្លូវ ។ គ្រានោះមានគី១នៅរសរួចលោតចេញពីកញ្ជ្រែងធ្លាក់ទៅក្នុងទឹកថ្លុកនោះ ឯងគីនោះ ក៏ហែលទឹកទៅវិញទៅមក ក្នុងថ្លុកនោះមានសត្វកង្កែប១ នៅអាស្រ័យជាលំនៅខ្លួន កង្កែបនោះបានឃើញគីហែលទឹកថ្លុកខ្លួនដូច្នោះ ពុំស្គាល់ថាជាសត្វអ្វី ទើបលោតមកតម្រាមគីនោះថា "ប្រស្តែងឯងនេះ ជាតិពីដើមតើនៅឯណា



ឃើញមិនដែលយល់ទេឡើយ" ។ គីនោះឃើញកង្កែបក៏ខ្លាច ទើបបង្អោនកាយនិយាយដោយពាក្យគួរថា "ខ្ញុំបាននេះហៅថាសត្វគីអាស្រ័យនៅទឹមហាសាគរ គឺសមុទ្រ ព្រះតេជព្រះគុណត្រូវការសួរដោយហេតុអ្វី? ។ កង្កែបក៏សួរទៅថា "អើប្រស្តែង ទឹកសមុទ្រសាគរនោះជាធំទូលាយទៅប៉ុនណា? ។ គីប្រាប់ថា "ទឹកទឹកសមុទ្រនោះធំក្រែពេកណាស់មើលកោះមើលត្រើយមិនឃើញទេព្រះតេជព្រះគុណខ្ញុំបាទនឹងជំរាបថាប៉ុណ្ណេះប៉ុណ្ណោះនោះពុំបាន" ។ កង្កែបថា "មិនមែនទេប្រស្តែង បើជាធំណាស់ក៏ប៉ុនថ្លុកអញនេះឯង ដែលនឹងធំហួសថ្លុកអញនេះពុំមានអើប្រស្តែងមួយទៀតត្រីក្នុងសមុទ្រនោះ តើប៉ុនណាទៅហ៎ះ ។ គីប្រាប់ថា "ត្រីក្នុងសមុទ្រនោះធំៗ ណាស់ព្រះតេជព្រះគុណ ត្រីខ្លះមានខ្លួនវែង១០ ព្យាមក៏មាន ១០ហត្ថក៏មាន ធំប៉ុនភ្នំប៉ុនកោះក៏មាន ខ្ញុំបាទពណ៌នាជំរាបមិនអស់ទេឡើយ" ។

កង្កែបឮដូច្នោះក៏ថា "អាកុហកអើយ អាកុហកអញមិនជឿទេ បើដូច្នោះខ្លួនអាឯងនៅសមុទ្រដែរម៉េចក៏មិនធំដូចពាក្យអាឯងថានោះទៅ" ។ គីឮកង្កែបថាដូច្នោះ មិនហ៊ានប្រកែកតបតដោយក្តីខ្លាច ក៏ស្ងៀមនៅ ខំហែលជ្រកតាមគៀនថ្លុក

លាក់ខ្លួនខ្លាចកង្កែបនោះហោងៗ

រឿងនេះបានសេចក្តីដល់បុគ្គលល្ងង់ខ្លៅ ដែលបានចេះដឹងវិជ្ជាតិចតួច ឬមានទ្រព្យសម្បត្តិតិចតួចសំគាល់ខ្លួនថា គ្មានវិជ្ជាឯណាឲ្យលើសនេះទៅទៀតដែលខ្លួនមិនចេះនោះ ឬសំគាល់ថាទ្រព្យសម្បត្តិនេះគ្មាននរណាមានស្មើអាត្មា លើសអាត្មាទៅទៀតទោះមានគេមកសរសើរពីមហាប្រទេសថា មានអ្នកមានសម្បត្តិបរិបូណ៌វិសេស ទាំងវិជ្ជាចំណេះក៏មានគេចេះច្រើនណាស់ ឮយ៉ាងនេះក៏នៅមិនជឿគេ នៅតែអួតទ្រព្យសម្បត្តិខ្លួន អួតចំណេះវិជ្ជាខ្លួននោះឯងៗ បទកង្កែបអួតទឹកថ្លុកនោះ សមដោយបទព្រះបាលីក្នុងលោកនីតិថា៖

អប្បសុតោ សុតំ អប្បំ
ពហុមញ្ញតិ មានវា
សិន្ធុនកំ អប្បសន្តោ
កុបេ តោយំវ មណ្ឌុកោ។

ប្រែថា "ខ្លៅប្រៀនរៀនត្រាប់ស្តាប់តិចតួច សំគាល់ថាខ្លួនស្រួចចេះមិនទាល់ មិនដឹងពុទ្ធពចន៍នៅសែនសល់ដូចកល់កង្កែប



បែបកំឡៀៗ នៅក្នុងអណ្តូងរណ្តៅទាល់ មិនដែលទៅស្គាល់សមុទ្រជ្រៅ សំគាល់អណ្តូងដែលខ្លួននៅ ថាជ្រៅថាធំលើសនានា" ៗ

**ចប់តម្រាអ្នកខ្លៅដៅខ្លួនថាចេះអស់ ជាគតិទី ៤៩។**

## និទាននេះមានដំណាលក្នុងក្បួនបារាំងសែស

មានបុរសម្នាក់ ឈ្មោះចៅវ៉ីនចៅនោះជាមនុស្សល្ងង់ឆោតខ្លៅ ឃើញអ្វីៗក្តីឬធ្វើការអ្វីៗក្តី ពុំមានសាកសួរគេឲ្យដឹងហេតុដឹងបច្ច័យនោះឡើយ សឹងប្រមាណយកតែតាមគំនិតខ្លួនឯងថ្ងៃមួយចៅវ៉ីនដើរទៅលេង បានឃើញតាចាស់ម្នាក់ឈ្មោះតាឃ្លាំងគាត់ពាក់វ៉ែនតាមើលសាស្ត្រា ដោយភាវៈគាត់ជាមនុស្សចាស់ ចៅវ៉ីនឃើញហើយនឹកសំគាល់ក្នុងចិត្តឯងថា ដែលគេសមើលសាស្ត្រាមើលសំបុត្រនោះ គឺគេមើលដឹងនឹងវ៉ែនតាទេតើ អើ បើដូច្នោះក្រអ្វីសព្វបើវ៉ែនតា មានគេលក់នៅផ្សារជាអនេខា អញនឹងទៅទិញយកមកពាក់មើលសាស្ត្រា មើលសំបុត្រដូចតាឃ្លាំងនេះក៏បាន គិតហើយចៅវ៉ីនយកប្រាក់១រៀលដាក់ក្នុងហោប៉ៅដើរទៅកាន់ហាង ដល់ហើយក៏ចូលទៅសួរថា "ផ្ទះអ្នកដង្ហៅនេះមានវ៉ែនតាលក់ទេ" ៗ

នាយហាងឆ្លើយប្រាប់ថា "មានចៅចង់ទិញបែបណាចូរថា មក"។ ចៅវ៉ែនថា "ខ្ញុំបាទត្រូវការតែវ៉ែនតាយ៉ាងល្អៗថ្លៃស្មើ១ រៀលសូមអ្នកដំឡៅយកមកពាក់មើល"។ នាយហាងក៏យកវ៉ែន តា១ ខ្នាតអាយុមនុស្សសាមសិបប្លាយ ហុចទៅឲ្យចៅវ៉ែន ហើយ ថា "ចៅឯងពាក់លមើលទៅ"។ ចៅវ៉ែនក៏ទទួលយកវ៉ែនតាមក ពាក់ហើយថា "ផ្ទះអ្នកដំឡៅមានកាកសំបុត្រខ្លះទេខ្ញុំនឹងពាក់ មើលអក្សរនោះល្បងមើល"។ នាយហាងឆ្លើយថាមាន ថា ហើយទៅយកកាកសំបុត្រ១ ផ្ទាំងហុចឲ្យទៅចៅវ៉ែនៗ ទទួល មកបើកមើលៗ ឃើញតែតួអក្សរមិនដឹងសេចក្ដីថាជាអ្វីៗ ឡើយ ចៅវ៉ែនមើលសំបុត្រមិនដាច់មិនដឹងដូច្នោះ ក៏ដោះវ៉ែន តាឲ្យទៅនាយហាងវិញហើយថាវ៉ែនតានេះ មិនស៊ីភ្នែកខ្ញុំបាទ ទេនាយហាងក៏រើសយកវ៉ែនតាថ្មី១ ហុចទៅឲ្យលម្ដងទៀត ចៅវ៉ែនពាក់មើលក៏ដូចមុន ទើបដោះឲ្យទៅនាយហាងវិញ នាយហាងផ្លាស់វ៉ែនតាឲ្យចៅវ៉ែនពាក់លមើលសំបុត្រនោះមិន តែ១ដង ២ដងឡើយ តើផ្លាស់អស់វ៉ែនតា១ឡូ ក៏មិនត្រូវភ្នែក ចៅវ៉ែនសោះនាយហាងផ្លាស់មិនឈ្នះក៏ខឹង និកថាវ៉ែនតាច្រើន ដល់ម៉្លេះក៏នៅតែមិនត្រូវ ទើបយកវ៉ែនតា១ យ៉ាងល្អឲ្យចៅវ៉ែន



ពាក់មើលទៀត ហើយទៅលបមើលពីក្រោយខ្នងចៅវ៉ែនកំពុង មើលសំបុត្រ ចៅវ៉ែនមិនចេះអក្សរ កាន់សំបុត្រមើលច្រាស ជើងអក្សរលើជាក្រោម នាយហាងឃើញខុសដូច្នោះ ក៏និកថា អានេះមិនចេះអក្សរទេដឹង បានជាមើលច្រាសជើងអក្សរ យ៉ាងនេះ គិតហើយក៏សួរថា "ចៅឯងមិនចេះអក្សរទេដឹង បាន ជាមើលសំបុត្រផ្កាសច្រាសលើជាក្រោមយ៉ាងនេះ"។ ចៅវ៉ែន តបថា "បើខ្ញុំចេះអក្សរហើយចាំបាច់មកទិញវ៉ែនតានេះ ឲ្យ បង់ប្រាក់ទទេធ្វើអ្វី"។

នាយហាងឮដូច្នោះ ក៏ដឹងថាចៅវ៉ែនមិនចេះអក្សរមកទិញ វ៉ែនតាពាក់មើលអក្សរឲ្យដាច់ ទើបនាយហាងសើចខឹងផង និយាយទៅថា "អើចៅអើយ មនុស្សក្នុងលោកនេះរកក្រមាន ដូចចៅឯងណាស់ ចៅឮនរណាថាមនុស្សមិនរៀនអក្សរហើយ មកទិញវ៉ែនតា ពាក់មើលអក្សរដាច់បាន វ៉ែនតាមនុស្សលោក ដែលពាក់មើលអក្សរដាច់នោះមិនដែលមានទេ ក្រែងតែ វ៉ែនតាខ្មោចនោះ ទើបពាក់មើលអក្សរដាច់បាន បើដូច្នេះ ចៅទៅរកទិញវ៉ែនតាខ្មោចចុះ វ៉ែនតាមនុស្សគ្មានទេចៅឯង ពេញជាឆ្កួតពិតប្រាកដ ធ្វើឲ្យយើងនឿយហត់នឹងការរើផ្លាស់

វ៉ឺនតាយកចេញយកចូលឲ្យពាក់មើលព្រើលយ៉ាងនេះ ចូរចៅ
ទៅផ្ទះចៅឲ្យឆាប់ កុំនៅចាំតទិញវ៉ឺនតាឯណាទៀតឡើយ"ៗ

ចៅវ៉ឺនបានឮនាយហាងត្នះតិះដៀលដូច្នោះ កើតខ្មាសពួក
អ្នកផង្សារ ទើបចុះចរយាត្រាទៅផ្ទះខ្លួនវិញហោងៗ

រឿងនេះបានគតិដូចបុគ្គលអ្នកឃើញអ្វីឮអ្វីហើយស្មានយក
ដោយគំនិតខ្លួនឯង ដូចអ្នកខ្លះឃើញសម្លសៀមឬបានស៊ីសម្ល
សៀម ដែលស្លដោយម្ទេសឆ្អើរទឹកស្មានប្រមាណថា គេស្ល
ដោយមខ្លាញ់បង្កង បានជាប្រហមយ៉ាងនេះ មានអ្នកខ្លះឮគេថា
ធ្វើប្រេងដូងដោយដូងទុំ ក៏ស្មានថាគេកាប់ដូងយកសាច់មកលំអិ
តដាក់ឆ្នាំងរំងាស់ ឬលីងនឹងអំបែងឲ្យចេញប្រេងយ៉ាងនេះក៏
មាន អ្នកខ្លះបានស៊ីចំណីក្នុងក្រុងតែមិនដឹងជាគេធ្វើដូចម្តេចទៅ
ស្មានយកដោយយោបល់ខ្លួនឯងហើយបានក្តីទោមនស្ស ក្រោយ
វិញក៏មាន ដូចមាននិទាននិយាយថា កាលនោះមានអ្នកស្រែម្នាក់
មានសំឡាញ់ម្នាក់នៅក្នុងក្រុង សំឡាញ់នោះគេក៏ទទួលឲ្យសំ
ណាក់នៅ ដល់ពេលគេធ្វើបបរមៀនលើកមកឲ្យស៊ីតាមក្តីរាប់
អាន ចៅនោះបានស៊ីបបរមៀនផ្អែមឆ្ងាញ់ហើយក៏នឹកថា ផ្លែ
មៀននេះគេប្រើធ្វើបបរជាណាស់ដែរតើ ឯងមិនដឹងសោះ



ចាំទៅផ្ទះវិញនឹងប្រាប់នឹងប្រើប្រពន្ធឲ្យបបរ ចៅនោះគិត
តែដូច្នោះនឹងបានគិតសាកសួរវិធីបបរមៀននោះ ធ្វើដូចម្តេច
ខ្លះគេដាក់អ្វីខ្លះក៏ឥតអង្គីមាន លុះនៅអស់កិច្ចការខ្លួនហើយក៏
លាសំឡាញ់ទៅស្រុកអាត្មាវិញ និយាយប្រាប់ប្រពន្ធគីរឿង
បបរមៀននោះៗ នាងប្រពន្ធថាផ្លែមៀនយើងក៏មានបរិបូណ៌
តែយើងមិនដែលបបរទេឡើយ មិនដឹងជាគេដាក់អ្វីខ្លះ ចៅនោះ
ថាគ្មានដាក់អ្វីទេ ដាក់តែអង្ករដំណើបនឹងខ្ទិះដូងប៉ុណ្ណោះឯងៗ
នាងប្រពន្ធក៏ទៅបេះផ្លែមៀនយកមកបកដាក់ក្នុងឆ្នាំងដាក់
អង្ករដាក់ខ្ទិះដូង ហើយបបរតាមពាក្យប្តីបង្គាប់លុះឆ្អិនហើយ
ក៏ដួសយកមកឲ្យប្តី ចៅប្តីបបួលនាងប្រពន្ធស៊ីជាមួយគ្នា លុះស៊ី
ទៅមិនផ្អែមមិនផុំក្លិនមៀន ក៏ពោលថាកាលអញទៅស៊ីបបរ
សំឡាញ់នោះម្តេចក៏ផ្អែមហើយផុំក្លិនមៀនពិសាម៉្លេះ បបរយើ
ងនេះម្តេចមិនដូចបបរសំឡាញ់នោះហះៗ នាងប្រពន្ធសួរថា
"កាលអ្នកពិសាបបរសំឡាញ់រួចហើយនោះ តើអ្នកបានសួរគេ
ថាដាក់អ្វីខ្លះគេដាក់ស្ករដែរឬដូចម្តេច"ៗ ចៅប្តីថា "មិនបាន
សួរគេទេ យើងស្មានប្រមាណយកដោយខ្លួនឯងយ៉ាងនេះ ល្ហើយ
ចុះចាំទៅក្រោយទៀតសួរគេ ឯបបរនេះស៊ីមិនបានទេ ចូរឯង

ចាក់ចោលឲ្យឆ្កែឆ្មាវាស៊ីទៅចុះ" នាងប្រពន្ធក៏ចាក់បបរនោះ ចោលទៅដីអស់ហោង។

មួយទៀត អ្នកស្មានក្នុងការតែងតួក៏មាន មាននិទានដូចពួកអស់អ្នកក្នុងវាំងថា កាលនោះមានស្រីម្នាក់ឈ្មោះនាងសែងចន្ទ នៅក្នុងព្រះរាជវាំងហ្លួងនាងនោះទេលាលាបម្សៅរមៀត នាងយកសាប៊ូក្រអូបយ៉ាងល្អលាយនឹងផង់រមៀតលាបកាយ ហើយងូតទឹកដុសខាត់កាយដោយទឹកសាប៊ូរមៀតនោះឯង អំណាចសាប៊ូផង់រមៀតចូលសាច់ ក៏ឡើងសម្បុរបំព្រងល្អ គ្រានោះមានស្រីម្នាក់ឃើញនាងសែងចន្ទលាបម្សៅរមៀតល្អដូច្នោះក៏ស្មានប្រមាណយកដោយខ្លួនឯង ទើបយកកំបោរលាយនឹងផង់រមៀតលាបកាយខ្លួន អំណាចកំបោរត្រូវរមៀត ក៏ឡើងពណ៌ក្រហមដល់ស្លូតទៅកស្រមែកស្រមោកយល់អាក្រក់ មិនគួរស្នេហាឡើង ហើយបានទទួលពាក្យតិះដៀលអំពីនាងសែងចន្ទដោយប្រការផ្សេងៗហោង។

មួយទៀតមានស្មានយកក្នុងលាភសក្ការៈក៏មាន មាននិទានដូចមន្ត្រីម្នាក់ជាចៅក្រមសាលា គ្រាកាលនោះ មានកូនក្តីម្នាក់ត្រូវគេចោទដោយខ្លួនប្រការខុស ពួកចៅក្រមបានបង្គាប់ឲ្យធ្វើ



ពាក្យឆ្លើយ ពាក្យចោទ ចៅនោះគិតនឹងចង់សូកចៅក្រម លុះចៅក្រមបែរមកត្រង់ចំមុខ ក៏លើកដៃមួយធ្វើត្រង់កទំនងដងវែក បង្ហាញទៅចៅក្រមនោះៗ ក៏ដឹងសេចក្តីថាចៅនោះសូកហើយ នឹកស្មានថាចៅនោះជូនសេះមួយ ឲ្យជួយឈ្នះចោទក្នុងរឿងក្តីនោះឯង ទើបជួយកែខៃធ្វើឲ្យក្តីចៅចម្លើយនោះបានឈ្នះចោទ តាមភារៈខ្លួនលោភអាមិសនោះឯង។ ឯចៅចម្លើយបានដឹងថាក្តីខ្លួនឈ្នះគេហើយ ក៏ត្រេកអរនឹកដល់គុណចៅក្រមជួយខ្លួន ទើបធ្វើវែកដោះបាយមួយយកទៅជូនចៅក្រមនោះៗក៏ថា "កាលឯងលើកដៃក្រងក់ជាន័យបង្ហាញទៅអញនោះ គឺឯងឲ្យសេះអញនេះម្តេចឯងយកវែកមកឲ្យអញវិញ អញក្រអ្វីអាវែកត្រឡាកដូង"។ ចៅនោះក៏ដំរាបថា "ដែលខ្ញុំបាទលើកដៃក្រងក់នោះ គឺខ្ញុំបាទសំដៅត្រង់រូបវែកនេះឯង ព្រោះដងវែកក្រងក់មានសណ្ឋានដូចដៃខ្ញុំបាទធ្វើបង្ហាញលោកក្នុងកាលនោះឯង ខ្ញុំបាទនឹងបានថាជូនសេះមួយដល់លោកកាលណា សូមលោកទទួលវែកមួយទុកប្រើដួសបាយក្នុងផ្ទះលោកចុះ ជាគុណូបការៈរបស់ខ្ញុំបាទជូន ព្រោះជួយក្តីខ្ញុំបាទបានឈ្នះចោទនោះឯង"។ ឯចៅក្រមនោះក៏ទាល់ប្រាជ្ញា និងថាអ្វីទៅទៀតពុំបាន

ព្រោះខ្លួនស្មានខុសហោង ៗ

រឿងនិទាន អ្នកស្មានប្រមាណខុសប្រាថ្នានោះ មានពិស្តារទៀតច្រើនណាស់ មិនអាចនឹងពណ៌នាអញ្ជើញប្រាជ្ញប្រើជាចូលចិត្តវិចិត្រដោយរឿងចៅវ៉ែនជាបែបហោង ៗ

វ៉ែនអើយចៅវ៉ែន ល្ងង់អ្វីសល់សែន ក្នុងដែនគោកធ្លក អក្សរមិនរៀន របៀនមិនរក ចៅតិតស្មានយក កែវឆ្នុះសាស្ត្រា ៗ គេចេះគេចាស់ គេមើលមិនច្បាស់ គេពាក់វ៉ែនតា វ៉ែនឯងមិនចេះ ត្រិះខុសសញ្ញា នឹងមានវ៉ែនតា ឯណាមើលដាច់ ៗ

**ចប់តម្រាស្មានខុសជាគតិទី ៥០ ។**

មានបុរសម្នាក់ឈ្មោះចៅទ្រិស ជាជាតិអ្នកនៅស្រុកចំការលើ បានមកនៅក្នុងក្រុងព្រះនគរហើយបានស្ត្រីពួកអស់អ្នកក្នុងវាំងជាភរិយា ឯនាងភរិយានោះ តែប្ដីផុតធុរៈការកាលណាតែងប្រដៅប្ដីឲ្យរៀនពាក្យភាសារាជសព្ទរឿយៗ ព្រោះខ្លួននៅបំរើពួករាជត្រកូលក្នុងព្រះរាជវាំង ឯចៅទ្រិសឧស្សាហ៍ទន្ទេញរាជសព្ទចាំបានស្ទាត់គ្រប់សព្ទ តែពុំមានប្រាជ្ញានឹងគិតថាសព្ទអស់នេះ និយាយបានតែចំពោះរាជត្រកូលមួយនោះក៏ទេ គិតសំគាល់ថាសព្ទអស់នោះនិយាយបានទូទៅទាំងអស់គ្រប់រូប



មនុស្ស លុះនៅយូរមកមានកាលថ្ងៃមួយចៅទ្រិសទៅរកនេសាទត្រីក្នុងទន្លេ បានហើយក៏ដាក់ទូកចែវចូលទៅលក់នៅនាកំពង់ផ្សារត្រី ហើយស្រែកពពាយបាយថា "អើ អស់លោកអ្នកទាំងអស់គ្នា សូមអញ្ជើញយាងចុះមកទិញមច្ឆាយកទៅធ្វើក្រយាស្ងោយសោយ តាក្ដីប្រាថ្នា" ៗ ឯបណ្ដាអ្នកកំពង់ទាំងឡាយក៏នាំគ្នាទៅទិញត្រីសួរថ្លៃថា "អានេះតើថ្លៃវាប៉ុន្មាន? ៗ ចៅទ្រិសក៏ប្រាប់ថា "អានេះនៅមានព្រះជន្ម ថ្លៃវាពីរដម្លឹងអានុះទើបតែនឹងសោយព្រះទិវាល័យក្ស័យព្រះជន្មា ថ្លៃវាតែមួយដំឡឹងពីរបាទទេ នឹងអានុះបែកព្រះសិរ ចេញព្រះលោហិតនៅស្រស់ៗ ថ្លៃវាតែប្រាំបាទទេ ទ្រង់អញ្ជើញទិញយកចុះ ៗ ឯមហាជនទាំងឡាយបានឮចៅនោះនិយាយរាជសព្ទដូច្នោះ អ្នកខ្លះសើចអ្នកខ្លះហាមថាកុំនិយាយយ៉ាងហ្នឹងជាទីរំខាន ត្រចៀកអ្នកនគរណាស់ឯចៅទ្រិសមិនស្ដាប់មិនតាមគេបង្គាប់ ចេះតែនិយាយរាជសព្ទនោះដដែល ៗ គ្រាកាលនោះមានចៅម្នាក់រំខានត្រចៀកខ្លាំងណាស់ អត់ពុំបាន ក៏ក្រោកទៅទះមាត់ចៅទ្រិសៗខឹងហើយនិយាយទៅថា "អ្នកឯងទិញត្រី ហេតុអ្វីក៏យកព្រះហស្តមកទះព្រះឱស្ឋខ្ញុំយ៉ាងនេះ បើអ្នកឯងមិនទ្រង់ទិញក៏តាម

ព្រះរាជហឫទ័យចុះអេះ"ៗ ឯអ្នកដែលទះនឹងអ្នកទិញទាំងអស់
នោះ លុះបានឮពាក្យចៅនោះពោលដូច្នោះ ក៏នាំគ្នាសើចកងរំ
ពងឡើង ហើយត្មះតិះដៀលថា "អ្នកឯងនេះជាមនុស្សមិនដឹង
ប្រមាណក្នុងពាក្យនិយាយ គួរឬរាជសព្ទនេះ សម្រាប់និយាយតែ
ក្នុងត្រកូលមានស្តេចគ្រងរាជ្យជាដើម មិនដែលមានយកមក
និយាយលាយរាស្ត្រសព្ទស្តាប់រំខានត្រចៀកយ៉ាងនេះទេ នែចៅ
អើយ ចៅឯងកុំថ្លែងពាក្យស្តេចបញ្ចូលនឹងពាក្យរាស្ត្រទៅ
ទៀតឡើយ ៗ ឯចៅទ្រិស លុះបានឮគេត្មះតិះដៀលដូច្នោះក៏
នឹកខឹងមហិមា តែមិនហ៊ានថាអ្វីតនឹងគេទៅទៀត ខំឆ្លៀតលក់
ត្រីទាល់តែអស់ ហើយក៏ចែវទូកវិលផ្ទះ ដល់ហើយក៏បន្ទោស
ប្រពន្ធថា "អើម៉ែអាទូច ឯងបង្ហាត់បង្ហាញអញឲ្យរៀនរាជ
សព្ទនោះ អញខំទន្ទេញទំរាំចាំចេះបាន អញនឹកស្មានថារាជ
សព្ទនោះ ជាពាក្យខ្ពស់ពាក្យពីរោះ ឥឡូវត្រឡប់ជាមានគ្រោះ
ឲ្យគេគោះមាត់សើងនឹងបែក" ថាហើយក៏នាំសេចក្តីដែលខ្លួនទៅ
លក់ត្រី បានពោលរាជសព្ទត្រូវអ្នកផ្សារគេទះមាត់ឃាត់មិនឲ្យ
និយាយនោះ មកសារសព្ទប្រាប់នាងប្រពន្ធសព្វប្រការ ៗ

ឯនាងភរិយាដឹងការដូច្នោះក៏សើចញឹមៗ ហើយថា "ខ្ញុំឲ្យអ្នក



រៀនរាជសព្ទទុកសម្រាប់និយាយតែក្នុងរាជត្រកូលទេ នឹងបាន
ឲ្យទៅនិយាយលាយនឹងរាស្ត្រសព្ទគឺភាសារាស្ត្រនោះកាលណា
ខ្ញុំនឹកស្មានថាអ្នកចូលចិត្តសេចក្តីអស់ហើយ បានជាមិនហាមអ្នក
ក្នុងកាលនិយាយនឹងរាស្ត្រដូចគ្នានោះ អើថ្ងៃនេះទៅចូរអ្នកចាំ
ទុកចុះ បើបានចូលទៅគាល់ហៀព្រះបរមរាជាសឹមអ្នកនិយាយ
រាជសព្ទនេះ បើនិយាយនឹងរាស្ត្រដូចគ្នាទេត្រូវនិយាយរាស្ត្រសព្ទ
តាមធម្មតារាស្ត្រទៅចុះ"ៗ

រឿងនេះបានគតិអ្នកឆោតអ្នកទិដ្ឋិប្រកាន់តម្រាដើម ដែល
ខ្លួនបានរៀនមក ពុំដឹងវិធីតំរានោះជាគេប្រើក្នុងសម័យណា
ចេះតែប្រើទួទៅផ្តាស បានក្តីខុសយ៉ាងចៅទ្រិសនោះឯង មួយ
ទៀតដូចអ្នកប្រៀនពួកខ្លះ បានរៀនភាសាបាលីចាំចេះ ហើយ
ប្រកាន់ភាសាបាលីតែក្នុងភាគមួយ គឺភាសាបាលីនោះលោកអាច
ពោលឡើងសឹងដាក់តួការន្តពេញតួស្រះទាំង ៨ ដូចសព្ទថា
សុខៈ មុខៈ សប្បាយៈ បទៈ និមន្តៈ សម្បត្តិ ជាតិ ធាតុ ហេតុ យ៉ាង
នេះជាដើមដល់មកនិយាយលាយនឹងភាសាខ្មែរយើង បុរាណលោ
កអានចោល អការន្ត ឥការន្ត ឧការន្ត បង់ចេញ លោកអានថា
តួសង្កត់ខ្យល់ថា សុខ សប្បាយ និមន្តលោក កើតហេតុ អ្នកមាន

សម្បត្តិយ៉ាងនេះជាដើមវិញ អ្នកទៀនខ្លះប្រកាន់តែតាមសព្ទមានការន្ត ក្នុងកាលពោលពាក្យ ដូចក្នុងបទប្រយោគថាអ្នកឯងកាលបួសជាសាមណេរ នៅវត្តបទុមនោះជាធម្មយុត្តិឬជាមហានិកាយ នៅសុខសប្បាយជាទេគេនិមន្តលោកសង្ឃទៅសូត្រមន្តឲ្យលោកសូត្របទផ្ចាញ់មារ ក្នុងការធ្វើបុណ្យសាងកុសលយកមគ្គយកផល ទៅឯអនាគតខាងមុខ ពាក្យបាលី ចូរនិយាយលាយយ៉ាងនេះលោកពោលចោលអការន្តអស់ ហើយខ្លួនទៅពោលថាអ្នកឯងកាលបួសជាសាមណេរៈ នៅវត្តៈបទុមៈ នោះ ជាធម្មយុត្តិឬជាមហានិកាយៈ នៅសុខៈ សប្បាយៈជាទេ គេនិមន្តៈ លោកសង្ឃៈទៅសូត្រមន្តៈឲ្យលោកសូត្រទៈ ផ្ចាញ់មារៈ ក្នុងកាលៈធ្វើបុញ្ញៈសាងកុសលៈ យកមគ្គៈ យកផលៈ ទៅឯអនាគតៈ ខាងមុខៈ ពោលយ៉ាងនេះតាមភាសាបាលីត្រូវហើយតែខុសគេក្នុងនគរ គេស្តាប់កាលណា គេរំខានត្រចៀកគេដូចគ្នានឹងនិទានចៅទ្រិសពោលរាជសព្ទក្នុងប្រជុំជនបាននូវក្តីត្រូវគេទះមាត់នោះឯង អ្នកមានបញ្ញាគប្បីពិចារណាទៅទៀតចុះ ។

ទ្រិសអើយចៅទ្រិស ទិដ្ឋិជាឫស ដុះជាប់ចិន្តា មិនប្រែមិនស្រប សម្របភាសា ប្រកាន់តំរា ភរិយាគ្រូអាទិ៍ ។ មិនស្គាល់សម័យ



រូបគួរប្រស្រ័យ ចរចាតាមជាតិ ទៅពោលខុសកាល ដាលគេតិរិវាទ ត្រាំមាត់ត្រូវពាធ នឹងដៃអ្នកលែង ។

**ចប់តម្រាប្រើសព្ទខុសសម័យ ខុសរូប ជាគតិទី ៥១។**

មានសត្វទន្សាយមួយ ទៅដេកនៅក្រោមដើមព្នៅទៀបទីជើងដំបូកមួយ ថ្ងៃនោះមានផ្លែព្នៅមួយទុំ ដល់ពេលក៏ជ្រុះធ្លាក់ចាក់ទងដល់ដី សព្ទសូរឮប្រោកដោយខ្ទរទ្រៃ ។ ឯទន្សាយឮហើយ ក៏ភិតភ័យដោយគិតថាផែនដីស្រុត ទើបស្ទុះក្រោករត់ចេញទៅដោយកំលាំងផ្អើល បោលបោះថ្ពោះទៅដល់សំណាក់នៃគោៗ ក៏ស្រែកសួរថា "ទន្សាយអើយ ចៅរត់ខ្លាំងម្ល៉េះ តើដោយមានការអ្វី? ទន្សាយប្រាប់ថា "បងគោអើយ! ផែនដីស្រុតហើយ នៅនេះពុំបានទេទៅឲ្យឆាប់ៗ" ។ គោឮដូច្នោះ ក៏ភិតភ័យស្ទុះបោលទៅជាមុននៃទន្សាយ លុះបោលទៅដល់សំណាក់ក្រុមក្តាន់ៗ ក៏ផ្អើលរត់ទៅតាមគោៗ បោលទៅដល់សំណាក់ដំរីៗ ឃើញគោបោលមកក៏សួរថា "គោឯងបោលដោយមានការអ្វី? ។ គោថា "នៅនេះពុំបានទេមហាភ័យនឹងកើតមានដល់ពួកយើងហើយ" ។ ដំរីឮដូច្នោះហើយ ក៏ភ័យផ្អើលស្ទុះរត់ទៅជាមុននៃគោបានទៅដល់សំណាក់រាជសីហ៍បរមពោធិសត្វ ជាសត្វ

ប្រកបដោយសតិបញ្ញា កាលបានយល់ ពួកសត្វចតុប្បាទផ្អើលរត់ចលាចលដូច្នោះ ក៏សួរទៅដំរីថា "ប្រស្ដែងដំរី ឯងផ្អើលរត់មកតើព្រោះដំណើរអ្វី?ៗ ដំរីថា ខ្ញុំនេះមិនដឹងដំណើរអ្វីទេ ឃើញតែគោរបោលក៏រត់តាមគោមក ដោយឮថាមហាភ័យដល់ហើយ"ៗ

ពោធិសត្វក៏សួរទៅគោវិញថា "ប្រស្ដែងគោឯងនាំគេរត់មកនេះតើដោយហេតុអ្វី?ៗ គោតបថា "ខ្លួនខ្ញុំបាទក៏ពុំដឹងហេតុអ្វី ឃើញតែជ្រូកក្ដាន់ផ្អើលរត់ ក៏រត់តាមគេមក"ៗ ពោធិសត្វសួរជ្រូកក្ដាន់ៗ ក៏ប្រាប់ថាមិនដឹងដូចគ្នា តែអ្នកដែលផ្ដើមនាំរត់នោះ គឺសត្វទន្សាយនេះឯងជាមុនបង្អស់ៗ

រាជសីហ៍ពោធិសត្វ ក៏សួរទន្សាយៗប្រាប់ថាខ្ញុំបាទក៏ពុំច្បាស់ហេតុភ័យនោះ មិនដឹងជាសព្ទសូរអ្វីគឺកាលខ្ញុំបាទដេកនៅជើងដំបូក ដែលមានដើមព្នៅមួយដើមដុះនៅខាង កំពុងនិទ្រាលក់ស្រួលស្រាប់តែឮសូរសន្ធឹកប្រោកខ្លោក ខ្ទរផែនដីខ្ទប់ដល់ត្រចៀកខ្ញុំបាទៗ ភិតភ័យតក្កមាហាក់ដូចជាផែនដីស្រុតទ្រោមទ្រុឌ ឬកក្រើករំលើកញាប់ញ័រប្រោកដ ហេតុនោះបានជាខ្ញុំបាទរត់ចេញមកនេះ សូមអ្នករាជសីហ៍ជ្រាបហោង"ៗ



ពោធិសត្វឮទន្សាយអធិប្បាយដូច្នោះ ពិចារណាដោយបញ្ញាត្រិះរិះអាការសម្លេងនោះ ក៏ជ្រាបការឥតសង្ស័យ ទើបប្រស្រ័យទៅថា "អ្នកឯងអស់នេះជាសត្វឥតសតិបញ្ញា ហៅថាសត្វគំនិតស្រាល កាលឮអ្វី ឃើញអ្វី មិនទាន់ច្បាស់នឹងចក្ខុបញ្ញារបស់ខ្លួនក៏គិតស្មានប្រមាណ ហើយភ្ញាក់ផ្អើលភិតភ័យតាមគ្នានាំឲ្យលំបាកកាយ អស់កំលាំងទទេយ៉ាងនេះយើងគិតទៅយល់ហើយ រឿងសព្ទសូរប្រោកខ្លោកនោះ មិនមែនអ្វីទេ គឺផ្លែឈើធ្លាក់ចាកទងនោះឯងជាប្រោកដ ដូច្នេះចូរចៅទន្សាយឯងនាំយើងទៅមើលទីនោះ"ៗ ឯទន្សាយក៏នាំពោធិសត្វទៅត្រង់ទីជើងដំបូកដែលខ្លួនដេកនោះ ពោធិសត្វដើរមើលទីនោះ ក៏បានឃើញផ្លែព្នៅទុំមួយយ៉ាងធំ ដែលទើបនឹងជ្រុះមកថ្មីៗនៅទីនោះ ទើបប្រាប់អស់សត្វទាំងឡាយ មានទន្សាយជាដើមឲ្យចូលចិត្តថា មហាភ័យដែលកើតដល់អ្នកឯងរាល់គ្នានេះ គឺផ្លែព្នៅទុំមួយនេះឯង យើងរកឃើញហើយៗ ឯសត្វទាំងឡាយបានដឹងហេតុដើមគឺរាជសីហ៍រកឃើញហើយ ក៏នាំគ្នាឲ្យសព្ទសាធុការដល់ពោធិសត្វ ហើយត្មះតិះដៀលខ្លួនឯងដោយឥតសតិបញ្ញានឹងពិចារណាការអ្វីៗគ្រាន់តែឮគេ ឬឃើញតែគេផ្អើល មិនសាក

សួរហេតុឲ្យច្បាស់ការនោះជាមុនសិន មិនដឹងថាជាអ្វីៗក៏ភិតភ័យផ្អើលឆោឡោឡាចលាចលឡើង នាំឲ្យខូចកំឡាំងខូចប្រយោជន៍អាត្មាទីទៃៗ សត្វទាំងឡាយនាំគ្នាសរសើរពោធិសត្វហើយក៏លាពោធិសត្វទៅកាន់លំនៅអាត្មាទីទៃៗរៀងៗ រឿងនិទាននេះមានសេចក្ដីពិស្ដារក្នុងគម្ពីរដីកាមហាសមយសូត្រឯណោះ អ្នកប្រាជ្ញគប្បីចូលចិត្តចុះៗ

រឿងនិទាននេះ បានគតិដល់បុគ្គលអ្នកមានគំនិតស្រាល ដាលជឿតែគេ គ្មានគិតត្រូវខុស ឲ្យដឹងដើមដឹងចុង គ្រាន់តែឮគេក៏បណ្ដោយផ្អើលរត់ទៅបាននូវក្ដីក្ដៅក្រហាយ ដូចពួកសត្វចតុប្បាទទាំងឡាយផ្អើលតាមទន្សាយនោះឯង អ្នកប្រាជ្ញគប្បីចូលចិត្តទៀតចុះៗ

ទន់អើយទន្សាយ ញ្ញៀផ្លាក់ជិតកាយ ហ្វាហថាដីស្រុត មិនមើលឲ្យជាក់ ទៅភ្ញាក់តក់ស្លុត រត់ស្ទើរនឹងផុត អស្វាតបស្វាតៗ ខំបោលខំបោះ ហាក់ដូចគេហោះ នាំសត្វចតុប្បាទ ឲ្យផ្អើលគ្រប់ប្រាណ រត់ពានព្រៃស្បាត មិនដឹងដើមអាទិ៍ ខ្មោចញៀវាលងៗ

**ចប់តម្រាកោលាហលតតយោបល់ ជាគតិទី ៥២។**

**ចប់ភាគទី ៨ តែប៉ុណ្ណេះ។**